ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

# សេចក្តីសង្ខេបលទ្ធផល
# នៃការត្រួតពិនិត្យការអនុវត្តផែនការសកម្មភាព
# និងការវាយតម្លៃការអនុវត្តថវិកា ប្រចាំឆ្នាំ២០១៥
# របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ


រៀបចំដោយ

**អគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**នាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ, ការិយាល័យផែនការថវិកា**



ចងក្រងលើកទី២ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦

# សេចក្តីសង្ខេប
# លទ្ធផលនៃការត្រួតពិនិត្យការអនុវត្តផែនការសកម្មភាព និងការវាយតម្លៃការអនុវត្តថវិកា ប្រចាំឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## ១. សេចក្តីផ្តើម

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចាប់ផ្តើមអនុវត្តថវិកាកម្មវិធីពេញលេញនៅឆ្នាំ២០១៥ ស្របតាមប្រកាសលេខ ០៦៨ សហវ.ប្រក ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១៤ ស្តីពីការដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញ។ ការត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តថវិកា ដែលរួមមានទាំងការពិនិត្យលើទិដ្ឋភាពហិរញ្ញវត្ថុ និងទិដ្ឋភាពសមិទ្ធកម្ម ត្រូវបានរៀបចំឡើងដោយអគ្គលេខាធិការដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (កសហវ.) ក្នុងមុខងារជាអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ ដើម្បីសម្រេចបានពេញមួយជុំនៃវដ្តថវិកា ស្របតាមគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី ដែលត្រូវបានដាក់ឱ្យអនុវត្តដោយប្រកាសលេខ ១៩១១ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤។

## ២. វឌ្ឍនភាព

សម្រាប់ថវិកាឆ្នាំ២០១៥ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រេចបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ដែលវឌ្ឍនភាពទាំងនេះ ត្រូវបានបែងចែកជាបីដំណាក់កាល គឺដំណាក់កាលរៀបចំថវិកា, ដំណាក់កាលអនុវត្តថវិកា និងដំណាក់កាលត្រួតពិនិត្យវាយតម្លៃការអនុវត្តថវិកា។

### ២.១ ការរៀបចំថវិកា

- សម្រេចបានផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៥-២០១៧ ដែលចែកចេញជាគោលបំណងគោលនយោបាយចំនួន០២, កម្មវិធីចំនួន ០៥ និងអនុកម្មវិធីចំនួន ១៦។

# ដ្យាក្រាមទី១៖ ការបែងចែកការទទួលខុសត្រូវលើរចនាសម្ព័ន្ធគោលនយោបាយ



- ឥណទានថវិកា ដែលត្រូវបានអនុម័តក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ រួមមាន÷
    - <u>ផ្នែកចំណូល</u> មានចំនួនសរុប ១៣ ៦០៨ ៤៧៦ លានរៀល ដែលត្រូវបានបែងចែកជាពីរ គឺចំណូលនៅថ្នាក់កណ្តាល (រួមមាន ១.ចំណូលពន្ធគយ, ២.ចំណូលពីពន្ធដារ និង ៣.ចំណូលក្នុងទីស្តីការក្រសួង) ចំនួន ១៣ ៦០៨ ៣២៥ លានរៀល និងនៅថ្នាក់មូលដ្ឋាន (មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត) ចំនួន ១៥១ លានរៀល
    - <u>ផ្នែកចំណាយ</u> រួមមានចំណាយចរន្តចំនួន ៤១២ ៦៣៧,៦ លានរៀល និងចំណាយមូលធន (ដែលត្រូវគ្រប់គ្រងដោយអគ្គនាយកដ្ឋានថវិកា) មានចំនួន ១៩៦ ៤១៩,៨ លានរៀល។

*ដ្យាក្រាមទី២÷ គម្រោងចំណូលប្រចាំឆ្នាំ២០១៥*



*ដ្យាក្រាមទី៣៖ គម្រោងចំណាយប្រចាំឆ្នាំ២០១៥*




## ២.២ ការអនុវត្តថវិកា

### <u>ការអនុវត្តចំណូល</u>

ការអនុវត្តចំណូលសម្រេចបានជារួម ចំនួន ១០ ៧១០ ៧៥៨,៣ លានរៀល ស្មើនឹង ៧៨,៧% នៃការកំណត់ក្នុងច្បាប់ ក្នុងនោះ ថ្នាក់កណ្តាលប្រមូលបាន ១០ ៧១០ ៤៣៥,២ លានរៀល ស្មើនឹង ៧៨,៧% និងថ្នាក់មូលដ្ឋានប្រមូលបាន ៣២៣,១ លានរៀល ស្មើនឹង ២១៤% នៃការកំណត់ក្នុងច្បាប់។ នៅថ្នាក់កណ្តាល ការអនុវត្តចំណូលគយ, ចំណូលពន្ធដារ និងចំណូលពីឧស្សាហកម្មហិរញ្ញវត្ថុ បានសម្រេចល្អលើសពីការកំណត់ក្នុងច្បាប់ ដោយចំណូលគយសម្រេចបាន ១១៥,៧%, ចំណូលពន្ធដារសម្រេចបាន ១១០,៤% និងចំណូលពីឧស្សាហកម្មហិរញ្ញវត្ថុសម្រេចបាន ១៤៩,៨%។ ទោះយ៉ាងណា តួលេខចំណូលសរុប ពុំសម្រេចបានតាមគោលដៅ ក្នុងនោះចំណូលនៅទីស្តីការក្រសួងសម្រេចបានត្រឹម ៤% ប៉ុណ្ណោះ ដោយហេតុថាពុំមានការរាយការណ៍ពីការប្រាក់នៃការឱ្យខ្ចី និងពីចំណូលមូលធន។

ដ្យាក្រាមទី៤÷ ការអនុវត្តចំណូលប្រចាំឆ្នាំ២០១៥




## <u>ការអនុវត្តចំណាយ</u>

ការអនុវត្តចំណាយថវិការបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានចំនួន ៣៩៨ ៩៨៥,៧ លានរៀល ស្មើនឹង ៩៦,៧% នៃឥណទានក្នុងច្បាប់ ក្នុងនោះ÷

- គោលបំណងគោលនយោបាយទី១ អនុវត្តបានចំនួន ៣ ៧៣៣,៦ លានរៀល ស្មើនឹង ១០១% នៃច្បាប់
    - កម្មវិធីទី១ អនុវត្តបានចំនួន ២ ០០១,៣ លានរៀល ស្មើនឹង ១៧០,៥% នៃច្បាប់
    - កម្មវិធីទី២ អនុវត្តបានចំនួន ១ ៧៣២,៣ លានរៀល ស្មើនឹង ៦៨% នៃច្បាប់
- គោលបំណងគោលនយោបាយទី២ អនុវត្តបានចំនួន ៣៩៥ ១៦២,១ លានរៀល ស្មើនឹង ៩៦,៦% នៃច្បាប់
    - កម្មវិធីទី៣ អនុវត្តបានចំនួន ២៣៥ ៤០៦,៧ លានរៀល ស្មើនឹង ៩៩,៥% នៃច្បាប់
    - កម្មវិធីទី៤ អនុវត្តបានចំនួន ៧ ១០៩,១ លានរៀល ស្មើនឹង ៨៧,២% នៃច្បាប់
    - កម្មវិធីទី៥ សម្រេចបានចំនួន ១៥២ ៦៤៦,៣ លានរៀល ស្មើនឹង ៩៣% នៃច្បាប់។

## ដ្យាក្រាមទី៥÷ ទិន្នន័យអនុវត្តចំណាយតាមគោលបំណងគោលនយោបាយ




## ដ្យាក្រាមទី៦÷ ទិន្នន័យអនុវត្តចំណាយតាមកម្មវិធី



ការអនុវត្តចំណាយតាមអនុកម្មវិធីនីមួយៗវិញ ក្នុងចំណោមអង្គភាពថវិកាសរុបចំនួន ១៦ មាន÷

- អង្គភាពថវិកាចំនួន ០៦ អនុវត្តថវិកាបានក្នុងរង្វង់ ៨០-១០០%
- អង្គភាពថវិកាចំនួន ០៤ អនុវត្តថវិកាលើសឥណទានកំណត់ក្នុងច្បាប់ ក្នុងនោះ អង្គភាពថវិកាចំនួន ០១ (អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ) អនុវត្តថវិការហូតដល់ ១៧១% នៃឥណទានក្នុងច្បាប់
- អង្គភាពថវិកាចំនួន ០៦ ផ្សេងទៀត អនុវត្តថវិកាបានតិចជាង ៨០% នៃឥណទានក្នុងច្បាប់ ក្នុងនោះ អង្គភាពថវិកាចំនួន ០១ (គណៈកម្មការមូលបត្រកម្ពុជា) អនុវត្តបានតិចជាង ៤០%។

*ដ្យាក្រាមទី៧÷ ទិន្នន័យអនុវត្តចំណាយតាមមាតិកាសេដ្ឋកិច្ច*



### ២.៣ ការត្រួតពិនិត្យសមិទ្ធកម្ម

វឌ្ឍនភាពសមិទ្ធកម្ម ដែលសម្រេចបានធៀបនឹងសូចនាករដែលបានកំណត់ក្នុងផែនការសកម្មភាពប្រចាំឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជារួមសម្រេចបានប្រមាណ ៨៧% ក្នុងនោះ÷

- គោលបំណងគោលនយោបាយទី១ សម្រេចបាន ៨៥%
    - កម្មវិធីទី១ សម្រេចបាន ៩០%
    - កម្មវិធីទី២ សម្រេចបាន ៨០%
- គោលបំណងគោលនយោបាយទី២ សម្រេចបាន ៨៨%
    - កម្មវិធីទី៣ សម្រេចបាន ៨៩%
    - កម្មវិធីទី៤ សម្រេចបាន ៩៤%
    - កម្មវិធីទី៥ សម្រេចបាន ៨៣%។

ក្នុងកម្រិតអនុកម្មវិធី មានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ដោយអនុកម្មវិធីភាគច្រើនសម្រេចបាន ក្នុងរង្វង់ពី ៧០% ដល់ ៩០% និងមានអនុកម្មវិធីចំនួន ០២ សម្រេចបាន ៩៨%។ ទន្ទឹមនេះ សូចនាករសមិទ្ធកម្មសំខាន់ៗមួយចំនួនដែលពុំទាន់សម្រេចបាន ត្រូវបានគូសបញ្ជាក់នៅក្នុងរបាយការណ៍លម្អិត រហូតដល់កម្រិតចង្កោមសកម្មភាព។

## *ដ្យាក្រាមទី៨÷ វឌ្ឍនភាពសមិទ្ធកម្មក្នុងកម្រិតគោលបំណងគោលនយោបាយ និងកម្រិតកម្មវិធី*




**គ្រប់គ្រងសេដ្ឋកិច្ច និងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ (៨៥%)**

**កម្មវិធីទី១**
ការគ្រប់គ្រងសេដ្ឋកិច្ច
៩០ %

៨០ %
**កម្មវិធីទី២**
ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ




**គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងទ្រព្យសម្បត្តិរដ្ឋ (៨៨%)**

**កម្មវិធីទី៣**
ការកៀរគរចំណូលថវិកាជាតិ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
៨៩ %

៩៤ %
**កម្មវិធីទី៤**
ការបង្កើនប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធ នៃការគ្រប់គ្រងចំណាយសាធារណៈ

**កម្មវិធីទី៥**
ការផ្តល់សេវាគាំទ្រទូទៅ និងគណនេយ្យភាពក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
៨៣ %

## ៣. សន្និដ្ឋាន

ការត្រួតពិនិត្យការអនុវត្តផែនការសកម្មភាព និងវាយតម្លៃការអនុវត្តថវិកាប្រចាំឆ្នាំ២០១៥ អាចធ្វើទៅបានដោយសារការប្រើប្រាស់សាកល្បងនូវតារាងតាមដានសន្និធិឥណទានតាមមាតិកាកម្មវិធី ដែលត្រូវបានអភិវឌ្ឍនៅផ្ទៃក្នុងអគ្គលេខាធិការដ្ឋាន សម្រាប់ជាជំនួយដល់ការកត់ត្រាការអនុវត្តថវិកានាឆ្នាំ២០១៥។ ការត្រួតពិនិត្យវាយតម្លៃនេះ ជាការងារថ្មី ដែលពុំទាន់អាចធានាសុក្រឹតភាពពេញលេញនៅឡើយ ដោយហេតុថាការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងផែនការសកម្មភាពប្រចាំ នៅមានកម្រិត រីឯការអនុវត្តថវិកាកម្មវិធីនៅពុំទាន់បានរលូននៅឡើយ។ ប៉ុន្តែ របាយការណ៍ត្រួតពិនិត្យវាយតម្លៃការអនុវត្តថវិកា នឹងផ្តល់ជាមូលដ្ឋានដ៏មានសារៈសំខាន់សម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងកញ្ចប់ថវិកាប្រចាំឆ្នាំ នាពេលខាងមុខទៀត។

# តារាងសង្ខេបការអនុវត្តថវិកា និងវឌ្ឍនភាពសមិទ្ធកម្ម តាមអង្គភាពថវិកា*

| អនុ-កម្មវិធី | អង្គភាព | ថវិកាចំណាយប្រចាំឆ្នាំ២០១៥ (គិតជាលានរៀល) | | | | | វឌ្ឍ.ធៀបសូច.សមិទ្ធ. |
|---|---|---|---|---|---|---|---|
| | | ច្បាប់ | ឥណទានថ្មី | អនុវត្ត | អនុវត្ត/ច្ប. | អនុ./ឥ.ថ្មី | |
| **គោលបំណងគោលនយោបាយទី១** | | **3.721,6** | **4.703,8** | **3.733,6** | **101,0%** | **79,4%** | **85%** |
| **កម្មវិធីទី១** | | 1.173,5 | 2.224,7 | 2.001,3 | 170,5% | 90,0% | 90% |
| ១.១ | អគ្គ.គោល.សេដ្ឋ.និងហិរ.សាធារ. | 1.173,5 | 2.224,7 | 2.001,3 | 170,5% | 90,0% | 90% |
| **កម្មវិធីទី២** | | 2.548,1 | 2.479,1 | 1.732,3 | 68,0% | 69,9% | 80% |
| ២.១ | អគ្គ.ឧស្សាហកម្មហិរញ្ញវត្ថុ | 1.222,0 | 1.213,0 | 985,2 | 80,6% | 81,2% | 90% |
| ២.២ | ក្រុមប្រឹក្សាជាតិគណនេយ្យ | 458,4 | 458,4 | 410,7 | 89,6% | 89,6% | 70% |
| ២.៣ | គណៈកម្មការមូលបត្រកម្ពុជា | 867,7 | 807,7 | 336,4 | 38,8% | 41,6% | 70% |
| **គោលបំណងគោលនយោបាយទី២** | | **408.916,0** | **424.567,4** | **395.162,1** | **96,6%** | **93,1%** | **88%** |
| **កម្មវិធីទី៣** | | **236.671,3** | 239.269,1 | 235.406,7 | 99,5% | 98,4% | 89% |
| ៣.១ | អគ្គ.គយនិងរដ្ឋាករកម្ពុជា | 208.703,2 | 215.064,2 | 213.791,5 | 102,4% | 99,4% | 92% |
| ៣.២ | អគ្គនាយកដ្ឋានពន្ធដារ | 20.462,6 | 17.016,1 | 15.669,4 | 76,6% | 92,1% | 83% |
| ៣.៣ | អគ្គ.ទ្រព្យ.រដ្ឋនិងចំ.មិន.សារ.ពន្ធ | 7.505,5 | 7.188,8 | 5.945,8 | 79,2% | 82,7% | 91% |
| **កម្មវិធីទី៤** | | 8.149,2 | 8.983,8 | 7.109,1 | 87,2% | 79,1% | 94% |
| ៤.១ | អគ្គនាយកដ្ឋានថវិកា | 2.574,9 | 2.494,9 | 1.465,5 | 56,9% | 58,7% | 98% |
| ៤.២ | អគ្គ.ហិរ.រដ្ឋបាលថ្នាក់ក្រោមជាតិ | 1.244,4 | 1.358,4 | 854,1 | 68,6% | 62,9% | 90% |
| ៤.៣ | អគ្គ.លទ្ធកម្មសាធារណៈ | 776,4 | 776,4 | 672,7 | 86,6% | 86,6% | 89% |
| ៤.៤ | អគ្គនាយកដ្ឋានរតនាគារជាតិ | 3.553,5 | 4.354,1 | 4.116,8 | 115,9% | 94,5% | 98% |
| **កម្មវិធីទី៥** | | 164.095,5 | 176.314,5 | 152.646,3 | 93,0% | 86,6% | 83% |
| ៥.១ | អគ្គលេខាធិការដ្ឋាន នៃ គ.ហ.ស | 1.622,0 | 1.622,0 | 1.088,6 | 67,1% | 67,1% | 76% |
| ៥.២ | អគ្គលេខាធិការដ្ឋាន កសហវ. | 141.649,3 | 153.106,0 | 132.632,0 | 93,6% | 86,6% | 85% |
| ៥.៣ | មន្ទីរ សហវ. រាជធានី-ខេត្ត | 19.955,0 | 20.535,6 | 19.095,6 | 95,7% | 93,0% | 92% |
| ៥.៤ | អគ្គាធិការដ្ឋាន | 551,6 | 666,0 | 646,2 | 117,2% | 97,0% | 75% |
| ៥.៥ | អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង | 317,6 | 384,9 | 272,5 | 85,8% | 70,8% | 86% |
| **សរុប** | | **412.637,6** | **429.271,2** | **398.895,7** | **96,7%** | **92,9%** | **87%** |

*តួលេខកែសម្រួលក្រោយពីការផ្ទៀងផ្ទាត់ជាមួយអគ្គនាយកដ្ឋានរតនាគារជាតិ បញ្ចប់ត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦។

**តួលេខសរុបនេះ ពុំបូកបញ្ចូលការអនុវត្តចំណាយ នៃ អគ្គលេខាធិការដ្ឋាន នៃ គ.ហ.ស ឡើយ ដោយហេតុថា អគ្គលេខាធិការដ្ឋាន នៃ គ.ហ.ស អនុវត្តថវិកាតាមនីតិវិធីរួមបច្ចុប្បន្នកម្មសម្រាប់គម្រោងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍។

# សមាសភាពក្រុមការងារ
# សម្រាប់ការត្រួតពិនិត្យការអនុវត្តផែនការសកម្មភាព
# និងការវាយតម្លៃការអនុវត្តថវិកា ប្រចាំឆ្នាំ២០១៥
# របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

| ល.រ | គោត្តនាម-នាម | មុខតំណែង |
|---|---|---|
| ១. | ឯកឧត្តមបណ្ឌិត **ហ៊ែល ចំរើន** | អគ្គលេខាធិការ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាន **ក.ប.ផ.ក** |
| ២. | លោក **យ៉េត វីណែល** | អគ្គលេខាធិការរង នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| ៣. | លោក **ឯក ចន្ធា** | ប្រធាននាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ |
| ៤. | លោក **អ៊ុក សុផា** | អនុប្រធាននាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ |
| ៥. | លោកស្រី **ហង់ ស៊ីបូរ៉ែន** | អនុប្រធាននាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ |
| ៦. | លោក **ព្រឿង ប្រូណិត** | ប្រធានការិយាល័យគណនេយ្យ |
| ៧. | លោក **សាយ អ៊ាន** | ប្រធានការិយាល័យផែនការថវិកា |
| ៨. | លោក **នុំ ម៉ុងហេង** | អនុប្រធានការិយាល័យផែនការថវិកា |
| ៩. | លោក **ឈាង ដាមី** | អនុប្រធានការិយាល័យផែនការថវិកា |
| ១០. | លោក **ឡៀង សុខតិរម្យ** | មន្ត្រីជំនាញ នៃអគ្គលេខាធិការដ្ឋាន នៃ គ.ហ.ស |
| ១១. | លោក **យន ម៉ាលីមឆេង** | មន្ត្រីជំនាញ នៃអគ្គលេខាធិការដ្ឋាន នៃ គ.ហ.ស |
| ១២. | លោកស្រី **សុគន្ធ ចរិយា** | មន្ត្រីជំនាញ នៃអគ្គលេខាធិការដ្ឋាន នៃ គ.ហ.ស |
| ១៣. | កញ្ញា **ហួត សំណាង** | មន្ត្រីការិយាល័យផែនការថវិកា |
| ១៤. | កញ្ញា **ខេមរិន្ទ រចនា** | មន្ត្រីការិយាល័យផែនការថវិកា |
| ១៥. | លោក **ហាក់ រដ្ឋា** | មន្ត្រីការិយាល័យផែនការថវិកា |
| ១៦. | កញ្ញា **ស៊ុម ច័ន្ទសូរិយា** | មន្ត្រីការិយាល័យផែនការថវិកា |
| ១៧. | លោក **ឈឹម ច័ន្ទដារ៉ូ** | មន្ត្រីការិយាល័យផែនការថវិកា |
| ១៨. | លោក **ផល សុលី** | មន្ត្រីជាប់កិច្ចសន្យា |
| ១៩. | លោក **ហ៊ឹម សុវណ្ណដារ៉ា** | មន្ត្រីជាប់កិច្ចសន្យា |

**អគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**នាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ, ការិយាល័យផែនការថវិកា**

បោះពុម្ពលើកទី២ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦